**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ : ៦៣៤ អយក.ប្រក**

# ប្រកាស

## ស្តីពីការបើកសាលាបឋមសិក្សា ហ៊ុន សែន ចន្លក់ ជាសាលាបឋមសិក្សាពេញលក្ខណៈ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខនស-រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញអនុក្រឹត្យលេខ ២១អនក្រ.ប.ក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំយុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ ១០៤ អនក្រ-បក ចុះថ្ងៃទី១៤ ខែ តុលា ឆ្នាំ ២០០២ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនាយកដ្ឋានបឋមនិងមត្តេយ្យសិក្សា ជានាយកដ្ឋានបឋមសិក្សា និង នាយកដ្ឋានអប់រំកុមារតូច

-បានពិនិត្យលិខិតលេខ ២៣១ ក-អយក ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុក កៀន ស្វាយ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៣ និងចំណារឯកភាពរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត **កណ្តាល** ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៣

-តាមយោបល់ឯកភាពរបស់ **នាយកដ្ឋានបឋមសិក្សា**

## សំរេច

**ប្រការ១** : បើកសាលាបឋមសិក្សា **ហ៊ុន សែន ចន្លក់** ដែលមានទីតាំងស្ថិតនៅភូមិ **ចន្លក់** ឃុំ **គគីរ** ស្រុក **កៀនស្វាយ** ខេត្ត **កណ្តាល** ជាសាលាបឋមសិក្សាពេញលក្ខណៈចាប់ពីឆ្នាំសិក្សា ២០០៣-២០០៤ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **ហ៊ុន សែន ចន្លក់** ត្រូវដឹកនាំដោយ នាយក១រូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេង ៗ ស្របតាមបទដ្ឋានប្រើប្រាស់ ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤** : អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានបឋមសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត **កណ្តាល** ការិយាល័យអប់រំ យុវជន និងកីឡាស្រុក **កៀនស្វាយ** នាយកសាលាបឋមសិក្សា **ហ៊ុន សែន ចន្លក់** មានភារកិច្ចអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ០១ ខែ [illegible] ឆ្នាំ ២០០៣

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

រដ្ឋលេខាធិការ

**អ៊ឹម សិទ្ធី**

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-ក្រសួងផែនការ-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្ត **កណ្តាល**

**"ដើម្បីជូនជ្រាបជាពត៌មាន"**

-ដូចប្រការ ៤

-កាលប្បវត្តិ-ឯកសារ នា .បស